ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

* * *

**ព្រះរាជក្រឹត្យ នស/រកត ០៧៩៧/១៤៤**

**ស្តីអំពីការបង្កើតក្រុងប៉ៃលិន**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីប្រមុខរាជរដ្ឋាភិបាល និងពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានបង្កើតក្រុងប៉ៃលិន ។ អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងក្រុងនេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : ក្រុងប៉ៃលិនត្រូវកាត់យកចេញពីភូមិសាស្ត្រមួយចំណែក របស់ខេត្តបាត់ដំបង និងត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោមនេះ ÷

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកកំរៀង ខេត្តបាត់ដំបង ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកសំឡូត ខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។

**មាត្រា ៣** : ទីតាំងសាលាក្រុងប៉ៃលិនស្ថិតនៅក្នុងសង្កាត់ប៉ៃលិន ។

**មាត្រា ៤** : ត្រូវបានបង្កើតខ័ណ្ឌចំនួន ២ ចំណុះក្រុងប៉ៃលិនគឺ : ខ័ណ្ឌប៉ៃលិន និងខ័ណ្ឌសាលាក្រៅ។

**មាត្រា ៥** : ខ័ណ្ឌប៉ៃលិនត្រូវបានបង្កើតសង្កាត់ចំនួន ៤ ចំណុះគឺ : សង្កាត់ប៉ៃលិន សង្កាត់អូរតាវ៉ៅ សង្កាត់ទួលល្វា និងសង្កាត់បយ៉ាខា ។

**មាត្រា ៦** : ខ័ណ្ឌប៉ៃលិនត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ខ័ណ្ឌសាលាក្រៅ ក្រុងប៉ៃលិន ។
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកសំឡូត ខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។

**មាត្រា ៧** : ទីតាំងសាលាខ័ណ្ឌប៉ៃលិន ស្ថិតនៅក្នុងសង្កាត់ទួលល្វា ។

**មាត្រា ៨** : ខ័ណ្ឌសាលាក្រៅត្រូវបានបង្កើតសង្កាត់ចំនួន៤ចំណុះគឺ : សង្កាត់សាលាក្រៅ សង្កាត់ស្ទឹងត្រង់ សង្កាត់ស្ទឹងកាច់ និងសង្កាត់អូរអណ្តូង ។

**មាត្រា ៩** : ខ័ណ្ឌសាលាក្រៅត្រូវបានកំណត់ព្រំប្រទល់ដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកកំរៀង ខេត្តបាត់ដំបង ។
- ខាងត្បូងទល់នឹងព្រំប្រទល់ខ័ណ្ឌប៉ៃលិន ក្រុងប៉ៃលិន ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៍ ។

មាត្រា ១០ :ទីតាំងសាលេ ស្ថិតនៅក្នុងសង្កាត់ស្ទឹងត្រង់ ។

មាត្រា ១១ :បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២ :នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល សហរដ្ឋមន្ត្រីទទួលបន្ទុកការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវ ទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ១៣ :ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៖

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គា

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

* * *

## II-រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

**អនុក្រឹត្យលេខ : ៣៣ អនក្រ.បក**

**ស្តីពី**

**ការត្រួតពិនិត្យហិរញ្ញវត្ថុនិងបទបញ្ជាផ្ទៃក្នុង**

**នៃគណនេយ្យសាធារណៈ ក្រសួងការពារជាតិ**

* * *

## រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា